# រឿង កំណើតសត្វរំពេ



# កំណើតឥសត្វរំពេ

និពន្ធដោយអ្នកស្រី កែវ សារុំ
គូររូបដោយលោក ចាន់ សោភ័ណ

រក្សាសិទ្ធិដោយ អង្គការសន្និស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០១០

រឿង **កំណើតសត្វរំពេ**



និពន្ធដោយ កែវ ណារុំ
វិចិត្ររូបភាពដោយ ចាន់ សោភ័ណ
បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត

ចៅឆើយកំព្រាម្ដាយតាំងពីតូច ។ គេរស់នៅជាមួយឪពុក លើកោះធំមួយកណ្ដាលសមុទ្រ ដោយប្រកបរបរធ្វើចំការ ។



តែតាំងពីតូចដល់ធំដឹងក្តី ចៅឆើយធ្វើការតែពីរមុខប៉ុណ្ណោះ គឺរកឧសនិង បង់សំណាញ់យកត្រី ។ ចំពោះការបំពេញការងារតែពីរមុខនោះ ចៅឆើយ នៅតែមានះទៀតដោយមិនស្តាប់ឪពុកទេ ។



នៅពេលឪពុកវាប្រើឱ្យទៅរកឧស ចៅឆើយបែរជាទៅបង់សំណាញ់ ។



តែបើឪពុកប្រើឱ្យទៅបង់សំណាញ់ ចៅឆើយបែរជាទៅរកឱសវិញ ។ ហេតុនេះហើយបានជាឪពុកគេដាក់ឈ្មោះថា "ឆើយ" ព្រោះវាតែងធ្វើឫក ឆើយដាក់ឪពុកជានិច្ច ។



ទោះបីជាឪពុកណែនាំកុំឱ្យរឹងទទឹង ឬជេរស្តីយ៉ាងណាក៏ដោយ ក៏ចៅឆើយមិនស្តាប់តាមដែរ ពោលគឺនៅតែប្រព្រឹត្តផ្ទុយនឹងបំណងរបស់ឪពុករហូត ។



នៅពេលចាស់ជរា ឪពុកចៅឆើយបានផ្តាំថា "ពេលពុកស្លាប់ទៅ ចូរកូនយកសពពុកទៅបោះចោលកណ្តាលសមុទ្រ គឺកុំកប់ក្រោមដើមរាំងភ្នំឱ្យសោះណា៎" ។



មួយខែក្រោយមក ឪពុកចៅឆើយក៏ទទួលមរណភាព ។ ពេលនោះ ចៅឆើយមានការសោកស្តាយយ៉ាងខ្លាំង ចំពោះចិត្តមានះដែលមិនបានបំពេញតាមបំណងរបស់ឪពុក ។



ហេតុនេះ គេក៏សម្រេចចិត្តបំពេញតាមបំណងរបស់ឪពុក គឺយកសពទៅ
ទម្លាក់ចោលកណ្ដាលសមុទ្រ ។



ប៉ុន្តែនៅពេលយប់នោះ ស្រាប់តែឪពុកមកពន្យល់សប្តិ ÷ "ការពិតពុកចង់ឱ្យកូនយកសពទៅកប់ក្រោមដើមរាំងភ្នំទេ! ចុះហេតុអ្វីបានជាកូនមិនធ្វើតាមទម្លាប់របស់កូនវិញ?" ។



ពេលភ្ញាក់ដឹងខ្លួន ចៅឆើយរឹតតែយំស្តាយស្រណោះចំពោះអំពើមិនគប្បី ដែលខ្លួនតែងប្រឆាំងនឹងសម្តីឪពុកជានិច្ច ។ ពេលនោះចៅឆើយក៏ស្ទុះរត់ទៅរាវរកសពឪពុកដើម្បីយកមកកប់ក្រោមដើមរាំងភ្នំវិញ ។



ប៉ុន្តែទោះបីជាចៅឆើយប្រឹងមុជរាវរកយ៉ាងណាក៏ដោយ   ក៏រកមិនឃើញដែរ ។ ចៅឆើយមុជរាវរករហូតដល់ហេវហត់ទន់ខ្លួនស្លាប់ក្នុងសមុទ្រនោះ ។



ពេលដែលស្លាប់ទៅ  ចៅឆើយបានកើតទៅជាសត្វស្លាបម្យ៉ាង ។ ដោយសារតែការស្ដាយក្រោយខ្លាំងពេក  ទោះបីកើតជាសត្វក៏ដោយនៅតែហិចហើរផ្ទៃលរកសពឪពុកបន្តទៀត ។



ដោយហេតុសត្វស្លាបនេះ តែងហើររំពៃគយគន់រកមើលសពជារៀងរាល់ថ្ងៃ ទើបអ្នកស្រុកនាំគ្នាហៅសត្វនោះថា "រំពេរំពៃ" ។ តែក្រោយមកក៏ហៅកាត់ខ្លីត្រឹមថា "រំពេ" តែប៉ុណ្ណោះ ។



ហេតុដូច្នេះហើយ   បានជាយើងឃើញមានសត្វរំពេជាច្រើនហិចហើរ នៅលើផ្ទៃសមុទ្រ   រហូតដល់សព្វថ្ងៃនេះ ។

ៜៜៜ ចប់ ៜៜៜ






អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association

9 789995 056308